# LASER PULSE

## សេវាផ្តល់ជំនួយផ្នែកស្រាវជ្រាវយូរអង្វែង **( LASER )**
## ដៃគូផ្តល់ដំណោះស្រាយប្រចាំសកលវិទ្យាល័យ **(PULSE )**

# របាយការណ៍ចុងក្រោយស្តីពីការសិក្សាពហុប្រទេសអំពីការអប់រំបរិយាបន្ន (**MCSIE)** របស់កម្ពុជា
# សេចក្តីសង្ខេប

បន្ថែមលើកិច្ចព្រមព្រៀងលេខ **AID-7200AA18CA00009**

ឈ្មោះ AOR៖ Kevin Roberts

ថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០២៣

ការបោះពុម្ពផ្សាយនេះអាចធ្វើទៅបានតាមរយៈការគាំទ្រដែលផ្តល់ដោយមជ្ឈមណ្ឌលច្នៃប្រឌិត បច្ចេកវិទ្យា និងស្រាវជ្រាវរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ តាមរយៈកម្មវិធី LASER PULSE ក្រោមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសហប្រតិបត្តិការលេខ 7200AA18CA00009។ មតិដែលបានបង្ហាញនៅទីនេះគឺជាគំនិតរបស់អ្នកនិពន្ធ(អ្នកនិពន្ធជាច្រើន) ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិនោះទេ។

## សេចក្តីថ្លែងអំណរគុណ

LASER (សេវាផ្តល់ជំនួយផ្នែកស្រាវជ្រាវយូរអង្វែង) PULSE (ម៉ាស៊ីនផ្តល់ដំណោះស្រាយប្រចាំសកល វិទ្យាល័យ) គឺជាកម្មវិធីដែលចំណាយអស់ ៧០ លានដុល្លារអាមេរិក ក្នុងរយៈពេល ១០ ឆ្នាំ ដែលត្រូវបានផ្តល់មូលនិធិតាមរយៈមជ្ឈមណ្ឌលច្នៃប្រឌិត បច្ចេកវិទ្យា និងការស្រាវជ្រាវរបស់ USAID ក្នុងការផ្តល់នូវដំណោះស្រាយដែលជំរុញការស្រាវជ្រាវចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍដែលមានប្រភព នៅក្នុងបណ្តាប្រទេសដែលមានការចាប់អារម្មណ៍របស់ USAID ។

សហព័ន្ធមួយដែលដឹកនាំដោយសាកលវិទ្យាល័យ Purdue ជាមួយដៃគូស្នូលនៃអង្គការ Catholic Relief Services ពីសាកលវិទ្យាល័យ Indiana សាកលវិទ្យាល័យ Makerere និងសាកលវិទ្យាល័យ Notre Dame អនុវត្តកម្មវិធី LASER PULSE តាមរយៈបណ្តាញអ្នកស្រាវជ្រាវដែលកើនឡើងដល់ជាង ៣.០០០ នាក់ និងអ្នកអនុវត្តការអភិវឌ្ឍក្នុង ៧៤ ប្រទេស។

LASER PULSE សហការជាមួយបេសកកម្មរបស់ USAID ការិយាល័យ និងការិយាល័យឯករាជ្យ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានផ្សេងទៀត ដើម្បីកំណត់នូវតម្រូវការស្រាវជ្រាវសម្រាប់បញ្ហាប្រឈមនៃការអភិវឌ្ឍន៍សំខាន់ៗ ព្រមទាំងផ្តល់មូលនិធិ និងពង្រឹងសមត្ថភាពក្រុមអ្នកស្រាវជ្រាវ-អ្នកអនុវត្ត ដើម្បីសហការរៀបចំដំណោះស្រាយ សម្រាប់យកទៅប្រើជាគោលនយោបាយ និងការអនុវត្ត។

ឯកសារនេះត្រូវបានបង្កើតឡើងដោយមានជំនួយពី USAID តាមរយៈ MCSIE។ ឯកសារនេះត្រូវបានកសាងឡើងដោយកិច្ចសហការរវាងដៃគូអភិវឌ្ឍន៍បរិយាបន្ន (IDP) អង្គការជនពិការកម្ពុជា(CDPO) សាកលវិទ្យាល័យ Massachusetts-Boston និងសាកលវិទ្យាល័យ Rowan ។ អ្នកនិពន្ធនាំមុខគេរបស់ឯកសារនេះ គឺលោកស្រី Hayley Niad លោក មាន វិបុលរតនៈ លោក Brent Elder លោកស្រី Valerie Karr និង លោកស្រី Emily Kochetkova ។ ឯកសារនេះមិនអាចកើតឡើងបានទេ ប្រសិនបើគ្មានការគាំទ្រយ៉ាងសកម្មក្នុងការប្រមូលទិន្នន័យ ការបញ្ចូលទិន្នន័យ និងកំណត់ត្រាពីអ្នកវាយតម្លៃរបស់អង្គការជនពិការកម្ពុជា ជាមួយនឹងការបកប្រែពីខ្មែរ-អង់គ្លេស និងអង់គ្លេស-ខ្មែរ ពីទីភ្នាក់ងារ Ahkara Translation ដោយរួមមានការគាំទ្រពី កញ្ញា ងួន សុភកណិកា ដែលជាទីប្រឹក្សារបស់ដៃគូអភិវឌ្ឍបរិយាបន្ន(IDP) និងជាមួយនឹងការវិភាគទិន្នន័យពីលោកស្រី Heike Boeltzig-Brown លោកស្រីបណ្ឌិត Alisha Braun និងលោកស្រី Jie Chen។

IDP សូមថ្លែងអំណរគុណដល់ក្រុមទីស្នាក់ការកណ្តាលរបស់ USAID ដែលបានចូលរួមយ៉ាងសកម្មក្នុងការរចនា និងការពិនិត្យឡើងវិញនៃការសិក្សានេះ។ សូមថ្លែងអំណរគុណចំពោះលោកស្រី Leah Maxson សម្រាប់ការ ពិនិត្យឡើងវិញ និងគំនិតយោបល់ និងសូមថ្លែងអំណរគុណចំពោះលោកស្រី Rebecca Pagel លោកស្រី Elena Walls លោក Brian Bingham លោក Kevin Roberts លោក Corrie Sutherland និងលោក Josh Josa សម្រាប់ការគាំទ្ររបស់ពួកគេលើឯកសារនេះ និងការវាយតម្លៃទាំងមូលរបស់ MCSIE ។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក រស់ សិរីសត្យា លោក Marc Bonnenfant និង លោក John Collins ដែលមកពី USAID Mission នៅកម្ពុជា និងចំពោះបុគ្គលិកអប់រំនៅការិយាល័យប្រចាំតំបន់អាស៊ីរបស់ USAID ។ លើសពីនេះ យើងសូមថ្លែងអំណរគុណដល់ក្រុមការងារគម្រោង គាំទ្រភាសាខ្មែរថ្នាក់ដំបូង (ACR) ទាំងអស់សម្រាប់ពេលវេលាដ៏មានតម្លៃ និងការគាំទ្រក្នុងការចែករំលែកព័ត៌មាន និងបទពិសោធន៍របស់ពួកគេ។ យើងក៏សូមកោតសរសើរចំពោះការគាំទ្ររបស់ក្រុម LASER ដែលមកពីសាកលវិទ្យាល័យ Purdue ហើយក៏ថ្លែងអំណរគុណដល់លោកស្រី Pamela McClure លោកស្រីបណ្ឌិត Betty Bugusu និង លោកស្រីបណ្ឌិត Yuehwern Yih។ ជាចុងក្រោយ យើងសូមថ្លែងអំណរគុណចំពោះលោកស្រី Catherine Frazier ដែលបានត្រួតពិនិត្យ និងកែសម្រួលឯកសារនេះ។ IDP ក៏សូមថ្លែងអំណរគុណចំពោះស្នាដៃរបស់លោកស្រី Rebecca Rhodes និងការរួមចំណែកទាំងអស់របស់នាងចំពោះគម្រោង MCSIE លោកស្រីធ្លាប់ជាសមាជិកដែលគួរឱ្យគោរព និងមានស្នាដៃខ្ពស់ក្នុងក្រុម។

## អក្សរកាត់

| | |
|---|---|
| ACL | គម្រោងកុមារទាំងអស់រៀនចេះ (ACL) |
| ACR | គម្រោងគាំទ្រភាសាខ្មែរថ្នាក់ដំបូង |
| AIM | ទីតាំងកំណត់ក្នុងការជួយ |
| ASL | ភាសាសញ្ញាអាមេរិក |
| CDPF | មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព |
| CDPO | អង្គការជនពិការកម្ពុជា (អ.ព.ក) |
| CLA | ការសហការ ការរៀនសូត្រ និងការសម្របខ្លួន |
| CSL | ភាសាសញ្ញាកម្ពុជា |
| DCHA | ជំនួយប្រជាធិបតេយ្យ ទំនាស់ និងមនុស្សធម៌ |
| DDP | កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ |
| EGR | អំណានថ្នាក់ដំបូង |
| EGRA | ការវាយតម្លៃអំណានថ្នាក់ដំបូង |
| EQ | សំណួរវាយតម្លៃ |
| FGD | សំនួរពិភាក្សាក្រុម |
| GPE | កម្មវិធីភាពជាដៃគូសកលសម្រាប់ការអប់រំ |
| IDP | ដៃគូអភិវឌ្ឍន៍បរិយាបន្ន |
| IP | ដៃគូអនុវត្ត |
| IVR | បច្ចេកវិទ្យាឆ្លើយតបជាសំលេង |
| KII | ការសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ |
| KT | អង្គការគ្រូសារថ្មី |
| LASER PULSE | សេវាផ្តល់ជំនួយផ្នែកស្រាវជ្រាវយូរអង្វែងសម្រាប់ដៃគូផ្តល់ដំណោះស្រាយប្រចាំសកលវិទ្យាល័យ |
| MCSIE | ការសិក្សាពហុប្រទេសលើការអប់រំបរិយាបន្ន |
| MEL | តាមដានការវាយតម្លៃ និងរៀនសូត្រ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | ក្រសួងសុខាភិបាល |
| NEP | អង្គការមិនមែនរដ្ឋាភិបាល ភាពជាដៃគូអប់រំ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NISE | វិទ្យាស្ថានជាតិអប់រំពិសេស |
| OPD | អង្គការជនមានពិការភាព |
| RTI | វិទ្យាស្ថានស្រាវជ្រាវត្រីកោណ |
| SED | នាយកដ្ឋានអប់រំពិសេស |
| TLM | សម្ភារៈបង្រៀន និងរៀន |
| UDL | វិធីសាស្ត្របង្រៀន និងរៀនបែបសកល |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ |

## ១. សេចក្តីសង្ខេប

USAID
បានបង្ហាញការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគាំទ្រការអប់រំសម្រាប់កុមារទាំងអស់នៅទូទាំងពិភពលោ
ករួមទាំងកុមារដែលមានពិការភាពផងដែរ។
ការប្តេជ្ញាចិត្តនេះបានឆ្លុះបញ្ចាំងនៅក្នុងគោលនយោបាយអប់រំរបស់ USAID ឆ្នាំ២០១៨ (USAID, 2018b)
និងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ឆ្នាំ ២០១៩-២០២៣ ស្តីពីការអប់រំជាមូលដ្ឋានអន្តរជាតិ
(USAID, 2018a)។ ស្របតាមការប្តេជ្ញាចិត្តនេះ USAID បានផ្តល់មូលនិធិដល់គម្រោង
និងកម្មវិធីនានាដែលគាំទ្រដល់ការសិក្សាថ្នាក់ដំបូងសម្រាប់សិស្សានុសិស្សដែលមានពិការភាព
និងគ្មានពិការភាព ដូចជាមាននៅប្រទេសកម្ពុជា ម៉ាឡាវី និងនេប៉ាល់។ MCSIE
មានគោលបំណងចងក្រងភស្តុតាង និងមេរៀនពិសោធន៍នានាជុំវិញការអនុវត្តកម្មវិធី
អំណានថ្នាក់ដំបូងប្រកបដោយបរិយាបន្ន។
របាយការណ៍នេះពិពណ៌នាអំពីការរកឃើញចុងក្រោយនៅក្នុងការវាយតម្លៃរបស់ ACR-Cambodia
ដែលជាគម្រោងអំណានថ្នាក់ដំបូងប្រកបដោយបរិយាបន្ន ដែលបានដំណើរការចាប់ពីខែកញ្ញា ឆ្នាំ២០១៦
ដល់ខែធ្នូ ឆ្នាំ ២០២១។
ACR-Cambodia
បានផ្តល់កម្មវិធីអំណានថ្នាក់ដំបូងភាសាខ្មែរកម្រិតបឋមដល់សិស្សចាប់ពីថ្នាក់មត្តេយ្យសិក្សាកម្រិតខ្ពស់
(ហៅថា "មត្តេយ្យសិក្សា" នៅក្នុងឯកសារនេះ) ដល់ថ្នាក់ទី ២ នៅក្នុងខេត្តគោលដៅ
ដោយផ្តោតលើការជួយដល់សិស្សទាំងមានពិការភាព និងគ្មានពិការភាព។
គម្រោងនេះបានចាប់ផ្តើមក្នុងឆ្នាំ ២០១៦ និងបញ្ចប់នៅឆ្នាំ ២០២១
ដែលបានអនុវត្តសកម្មភាពមួយចំនួនដូចជាការផលិតសម្ភារៈបង្រៀន និងរៀន (TLMs)
រួមមានសៀវភៅជំនួយបន្ថែមសម្រាប់សិស្ស សៀវភៅណែនាំសម្រាប់គ្រូបង្រៀន
និងធនធានសម្ភារៈដែលកែសម្រួលជាអក្សរប្រៃល៍ (ស្ទាប) និងភាសាសញ្ញាកម្ពុជា ការបណ្តុះបណ្តាលគ្រូ
និងការបង្ហឹកអំណានតាមសាលារៀន ការធ្វើតេស្តតាមសាលារៀន
ដើម្បីកំណត់អត្តសញ្ញាណកុមារដែលមានការលំបាកក្នុងការស្តាប់ ឬការមើល
និងតាមដានលទ្ធផលនៃការសិក្សារបស់សិស្សតាមរយៈការវាយតម្លៃអំណានថ្នាក់ដំបូង (EGRAs)។

## ១.១ ប្រវត្តិ និងគោលបំណងនៃការវាយតម្លៃ

USAID កំពុងចាប់ដៃគូជាមួយ IDP តាមរយៈយន្តការរបស់ LASER PULSE
ដែលដឹកនាំដោយសាកលវិទ្យាល័យ Purdue ដើម្បីធ្វើការវាយតម្លៃសកម្មភាពអប់រំបរិយាបន្នទាំងបីរបស់
USAID ដែលមាននៅក្នុងប្រទេស កម្ពុជា ម៉ាឡាវី និងនេប៉ាល់។ កិច្ចខិតខំប្រឹងប្រែងនៃការវាយតម្លៃនេះ
ហៅថា MCSIE ដើម្បីស្វែងរកមេរៀនពីអ្វីដែលមានដំណើរការល្អ សម្រាប់អ្នកណា
និងក្នុងបរិបទបែបណាដើម្បីជំរុញលទ្ធផលការបង្រៀន
និងការរៀនប្រកបដោយនិរន្តរភាពសម្រាប់កុមារពិការនៅក្នុងប្រទេសគោលដៅ។

ក្នុងករណីនៅប្រទេសកម្ពុជា អង្គការ IDP បានសហការជាមួយអង្គការ CDPO
ដើម្បីវាយតម្លៃនូវគំនិតផ្តួចផ្តើមនៃការអប់រំបរិយាបន្ននៅក្នុងគម្រោង ACR កម្ពុជា
ដែលដឹកនាំដោយវិទ្យាស្ថានស្រាវជ្រាវត្រីកោណ (RTI) អន្តរជាតិ។

## ១.២ វិធីសាស្ត្រ

របាយការណ៍នេះគឺជាការវាយតម្លៃចុងក្រោយនៃសកម្មភាពរបស់គម្រោង ACR-Cambodia
ដែលទាក់ទងនឹងការអប់រំបរិយាបន្នដែលបានបញ្ចប់នៅឆ្នាំ ២០២១។ IDP
ប្រើប្រាស់ការវាយតម្លៃលើដំណើរការគម្រោង
ដើម្បីបង្កើតករណីសិក្សានៃប្រព័ន្ធអប់រំបរិយាបន្ននៅក្នុងប្រទេសនីមួយៗ និងដើម្បីបង្ហាញថា
កអន្តរាគមន៍នានាដែលទទួលមូលនិធិពីUSAID មានផលជះយ៉ាងដូចម្តេចដល់ប្រព័ន្ធទាំងនោះ។
ប្រធានបទសំខាន់ៗចំនួនប្រាំផ្តល់នូវក្របខ័ណ្ឌសម្រាប់ការសិក្សា
និងបានជួយរៀបចំរចនាសម្ព័ន្ធរបាយការណ៍នេះ៖ (១) ដំណើរការរៀបចំ និងអនុវត្តគម្រោង (២)
ការធ្វើតេស្ត និងកំណត់អត្តសញ្ញាណសិស្សពិការ (៣)
គំរូនានានៃការបណ្តុះបណ្តាលគ្រូដែលគាំទ្រដល់កុមារដែលមានពិការភាព (៤)
គំរូនានានៃការបង្រៀនបែបបរិយាបន្នដើម្បីកែលម្អលទ្ធផលនៃការអាន និង (៥)
ផលវិបាកដែលមិនបានរំពឹងទុករបស់គម្រោង។
ដើម្បីបំភ្លឺលើប្រធានបទសំខាន់ៗ និងការរកឃើញនៅក្នុងប្រទេសកម្ពុជា ក្រុម IDP និង CDPO

បានប្រមូល ចំណុចទិន្នន័យរាប់ពាន់ក្នុងរយៈពេលជិតបីឆ្នាំ។
កិច្ចការនេះរួមបញ្ចូលទាំងការធ្វើបទសម្ភាសន៍អ្នកផ្តល់ព័ត៌មានសំខាន់ៗ (KIIs) ឬ សំនួរពិភាក្សាក្រុម (FGDs) ជាង ៣០០ ការស្ទង់មតិជាង ៤០០ ការបណ្តុះបណ្តាលឬការសង្កេតក្នុងថ្នាក់រៀន ចំនួន ១៥២ និងការពិនិត្យឡើងវិញលើប្រភពឯកសារបន្ទាប់បន្សំរបស់គម្រោង ជាង ២៨០ ។
ក្រុមអ្នកពាក់ព័ន្ធគឺមានសមាសភាពចម្រុះ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែបុគ្គលិកគម្រោង គ្រួសារ គ្រូបង្រៀន នាយកសាលា គ្រូបង្វឹកអំណាន តំណាងរដ្ឋាភិបាល និងអង្គការតំណាងជនមានពិការភាព (OPDs)1។ វិធីសាស្ត្រនេះ គឺសនៅមានកម្រិត រួមទាំងដំណើរការប្រមូលទិន្នន័យជាច្រើនពីចម្ងាយដោយសារតែមាននូវជំងឺរាតត្បាតកូវីដ-១៩។

## ១.៣ ចម្លើយសំណួរវាយតម្លៃ

សម្រាប់ប្រធានបទទាំងប្រាំនៃការសិក្សានីមួយៗ ទីភ្នាក់ងារ USAID បានបង្កើតសំណួរវាយតម្លៃ (EQ) ដើម្បីជូនដំណឹងអំពីការវាយតម្លៃនៃកម្មវិធីរបស់ប្រទេសនីមួយៗ
ក៏ដូចជាការសរសេរកម្មវិធីនៅក្នុងប្រទេសទាំងបី។
ខាងក្រោមនេះគឺជាការសង្ខេបនៃការរកឃើញទាំងនេះដោយយោងទៅតាម EQ ។

1. **ដំណើរការ៖** តើអ្វីដំណើរការបានល្អ/ខ្សោយក្នុងដំណើរការរៀបចំប្រព័ន្ធប្រកបដោយសមត្ថភាពប្រសិទ្ធភាព
និងនិរន្តរភាពដើម្បីផ្តោតលើការលើកកម្ពស់គុណភាពនៃការអប់រំសម្រាប់កុមារដែលមានពិការភាព?



**ចម្លើយ៖** ACR-Cambodia បានទទួលអត្ថប្រយោជន៍ពីការគ្រប់គ្រងគម្រោងដ៏ល្អ ដែលអនុញ្ញាតឱ្យបុគ្គលិកបង្កើនភាពជាដៃគូ និងការទំនាក់ទំនងជាមួយរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល (NGOs) ក្រុមគ្រួសារ
និងសមាជិកសហគមន៍ក្នុងលក្ខណៈសហការគ្នាយ៉ាងខ្លាំង
គាំទ្រយ៉ាងពេញលេញនូវគោលបំណងដើមនៃកំណែទម្រង់អក្ខរកម្មជាតិបែបទ្រង់ទ្រាយធំ ។ ជាទូទៅ កិច្ចការនេះអាចធ្វើទៅបាន
ទោះបីជាមានអ្នកជំនាញការអប់រំបរិយាបន្នក្នុងស្រុកនៅមានកម្រិតក៏ដោយ
ដែលជាបញ្ហាប្រឈមរបស់គម្រោងក្នុងការជ្រើសរើសបុគ្គលិក និងការអនុវត្តគម្រោង។
កង្វះការយល់ដឹងរបស់អ្នកពាក់ព័ន្ធអំពីពិការភាព
និងការអប់រំបរិយាបន្នគឺជាបញ្ហាខ្វះខាតដែលប៉ះពាល់ដល់ការអនុវត្តគម្រោងនៅក្នុងសហគមន៍សាលារៀន គួបផ្សំនិងបញ្ហាដែលមានក្រុមការងារអប់រំបរិយាបន្នដោយឡែក
ដែលតែងតែដំណើរការស្របគ្នាជាមួយនឹងក្រុមការងារផ្សេងទៀតរបស់គម្រោង។ លើសពីនេះទៅទៀត ទោះបីជានិរន្តរភាពនៃកញ្ចប់អំណានថ្នាក់ដំបូង (EGR)
ដែលបានបង្កប់ការអប់រំបែបបរិយាបន្នគឺទំនងជាមានកម្រិតខ្ពស់ ដោយសារតែធនធានមានកម្រិត សក្តានុពលនិរន្តរភាពនៃអន្តរាគមន៍ដែលផ្តោតលើពិការភាពអាចត្រូវបានកាត់បន្ថយ។

2. **ការពិនិត្យធ្វើតេស្ត និងកំណត់អត្តសញ្ញាណ៖**
តើវិធីសាស្ត្រអ្វីខ្លះដែលមានប្រសិទ្ធភាពបំផុតក្នុងការកំណត់អត្តសញ្ញាណសិស្សដែលមានពិការភាព?



**ចម្លើយ៖** ទោះបីជាមានការខិតខំប្រឹងប្រែងជាច្រើនក្នុងផ្នែកធ្វើតេស្តក៏ដោយ
ជាចុងក្រោយគម្រោងបានកំណត់ថា សកម្មភាពធ្វើតេស្តដំបូងៗរបស់ ACR-Cambodia ភាគច្រើនគ្មានប្រសិទ្ធភាពចំពោះកុមារដែលមានបញ្ហាក្នុងការស្តាប់ ឬការមើល
សម្រាប់បញ្ជូនពួកគេទៅធ្វើតេស្តបន្ត ហើយជាលទ្ធផល ការធ្វើរោគវិនិច្ឆ័យ
និងការគាំទ្រការតាមដានគឺមានការខ្វះខាតផងដែរ។ ជារួម
គម្រោងនេះបានកំណត់អត្តសញ្ញាណកុមារដែលមានពិការភាពក្នុងអត្រាទាបជាងការរំពឹងទុក។
សកម្មភាពពិនិត្យធ្វើតេស្តបានជួបប្រទះនឹងឧបសគ្គជាច្រើន រួមទាំងការប្រើឧបករណ៍ពិនិត្យការស្តាប់ដែលមិនអាចទុកចិត្តបាន និងកង្វះខាតក្នុងការអនុវត្តតេស្តជាក់ស្តែងរបស់ លោកគ្រូអ្នកគ្រូ។

---

[1] អង្គការជនមានពិការភាព (OPDs) ត្រូវបានគេស្គាល់ផងដែរថាជា អង្គការជនពិការ (DPOs) គឺជាអង្គការសង្គមស៊ីវិលដែលគ្រប់គ្រងដោយជនមានពិការភាព និងសម្រាប់ជនមានពិការភាព។

នៅពេលដែលកុមារត្រូវបានពិនិត្យធ្វើតេស្តនៅតាមសាលារៀន[2] គម្រោងបានរកឃើញថា សេវាបញ្ជូនបន្ត និងអ្នកឯកទេសផ្នែកសុខភាពនៅក្នុងប្រទេសកម្ពុជាមិនត្រូវបានរៀបចំ ដើម្បីគាំទ្រដល់កុមារដែលបានបញ្ជូនទៅនោះទេ ដែលជាការរារាំងដល់សមត្ថភាពរបស់គម្រោងក្នុងការពង្រីកកិច្ចខិតខំប្រឹងប្រែងក្នុងការពិនិត្យធ្វើតេស្ត ហើយជាហេតុធ្វើឱ្យមានការចោទជាសំណួរអំពីក្រមសីលធម៌សម្រាប់ការអនុវត្តតេស្តនាពេលខាងមុខ។ គម្រោងនេះបានផ្តោតលើអាត្រាសម្មតចំនួន១០% ដើម្បីគណនាសិស្សពិការក្នុងថ្នាក់រៀន។

**3. ការបណ្តុះបណ្តាល៖** តើគំរូបណ្តុះបណ្តាលមួយណាដែលដំណើរការបានល្អបំផុត ដើម្បីផ្តល់ធនធាន និងការគាំទ្រដល់គ្រូបង្រៀនដើម្បីបំពេញតម្រូវការរបស់កុមារដែលមានពិការភាពឱ្យបានល្អបំផុត?

**ចម្លើយ៖** ការវិភាគទិន្នន័យទាក់ទងនឹងការបណ្តុះបណ្តាលដែលប្រមូលបានតាមរយៈ MCSIE បានបង្ហាញថា ACR-Cambodia បានផ្តល់នូវវិធីសាស្ត្របណ្តុះបណ្តាលដែលមានការសម្របសម្រួលដ៏ល្អ ដែលគាំទ្រគ្រូបង្រៀនក្នុងការអភិវឌ្ឍជំនាញមូលដ្ឋានសម្រាប់ការបង្រៀនកញ្ចប់អំណានភាសាខ្មែរថ្នាក់ដំបូង។ គម្រោងនេះបានសហការយ៉ាងជិតស្និទ្ធជាមួយអ្នកពាក់ព័ន្ធរបស់រដ្ឋាភិបាលលើការអភិវឌ្ឍនូវខ្លឹមសារ និងការបណ្តុះបណ្តាលដែលបានប្រកាន់ខ្ជាប់នូវគោលការណ៍សិក្សាសម្រាប់មនុស្សពេញវ័យដោយផ្អែកលើភស្តុតាង[3] និងស្របតាមការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបសកល (UDL)។[4] សក្ខីកាមក៏បានរាយការណ៍ថា ជារួម ពួកគេមានការពេញចិត្តយ៉ាងខ្លាំងចំពោះកញ្ចប់បណ្តុះបណ្តាល ហើយមានការរិះគន់ ឬមិនពេញចិត្តបន្តិចបន្តួចដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តោតលើការអប់រំបរិយាបន្នទៅមានកម្រិត ដែលអាចជះឥទ្ធិពលដល់ការអនុវត្តការអប់រំបរិយាបន្នជាក់ស្តែងនៅក្នុងថ្នាក់រៀនរបស់គ្រូ។ ខណៈពេលដែលគោលការណ៍បរិយាបន្នដែលស្របតាម UDL ត្រូវបានបញ្ចូលទៅក្នុងកញ្ចប់អំណាន ការបណ្តុះបណ្តាលមិនបានភ្ជាប់យុទ្ធសាស្ត្របង្រៀនទាំងនេះទៅនឹងការអនុវត្តការអប់រំបរិយាបន្ននោះទេ។ គ្រូបង្រៀនក៏មិនបានភ្ជាប់ទំនាក់ទំនងរវាងការអប់រំបរិយាបន្ន ទៅនិង អត្តិភាពរបស់សិស្សពិការដែលមិនស្គាល់អត្តសញ្ញាណនៅក្នុងថ្នាក់រៀនរបស់ពួកគេដែរ ហើយជារឿយៗ តែងតែបង្ហាញការគាំទ្រចំពោះការអប់រំបរិយាបន្នជាទ្រឹស្តី ប៉ុន្តែពួកគាត់បានអះអាងថា វាមិនត្រូវបានអនុវត្តនាពេលបច្ចុប្បន្ននេះទេដោយសារថ្នាក់របស់ពួកគេគ្មានសិស្សមានពិការភាព។ ដោយសារការកែសម្រួលកញ្ចប់កម្មវិធីបណ្តុះបណ្តាលវិក្រឹតការទៅជាកម្មវិធីសម្រាប់បណ្តុះបណ្តាលនៅសាលាគរុកោសល្យ មិនបានពង្រីក ឬបន្ថែមការសង្កត់ធ្ងន់លើផ្នែកបរិយាបន្ន កញ្ចប់សម្រាប់បណ្តុះបណ្តាលនៅសាលាគរុកោសល្យក៏អាចបន្តមានចន្លោះខ្វះខាតដូចគ្នាផងដែរ។

4. **ការណែនាំ៖** តើគំរូការបង្រៀនណាដែលដំណើរការបានល្អបំផុតក្នុងការកែលម្អការបង្រៀន នៅក្នុងថ្នាក់ និងលទ្ធផលនៃការអានក្នុងចំណោមសិស្សមានពិការភាព?

**ចម្លើយ៖** ទោះបីជាមានការផ្តោតតិចតួចលើបរិយាបន្ន ឬ UDL ក្នុងអំឡុងពេលបណ្តុះបណ្តាលគ្រូក៏ដោយ គោលការណ៍បរិយាបន្នត្រូវបានបង្កប់ដោយប្រយោល (ហើយក្នុងករណីខ្លះគឺជាក់លាក់) នៅក្នុងសម្ភារៈបង្រៀន និងរៀន(TLMs) ហើយគ្រូបង្រៀននៅក្នុងសាលាគោលដៅបានបង្ហាញពីចំនេះដឹងកាន់តែច្រើនអំពីយុទ្ធសាស្ត្របរិយាបន្ន ក៏ដូចជាសមត្ថភាព របស់ពួកគេកំឡុងពេលអនុវត្តមេរៀនអំណាន បើប្រៀបធៀបជាមួយនឹងគ្រូនៅក្នុងក្រុមសាលាដែលមិនបានជាសាលាគោលដៅ ។ ទិន្នន័យដែលប្រមូលបានពីគ្រូបង្រៀន និងតាមរយៈការសង្កេតមេរៀនបានបង្ហាញពី តម្រូវការការងារបន្ថែមទៀតដើម្បីលើកកម្ពស់ការយល់ដឹងរបស់គ្រូបង្រៀនអំពីអត្តិភាពនៃពិការភាព "ដែលមើលមិនឃើញ" នៅក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ

---

[2] យោងតាមរបាយការណ៍បញ្ចាំងខែមិថុនា ឆ្នាំ 2019 គម្រោងបានពិនិត្យក្មេងប្រុសចំនួន 770 នាក់ និងក្មេងស្រី 695 នាក់ (n=1,465) នៅមត្តេយ្យសិក្សាខាងលើ និងក្មេងប្រុសចំនួន 2,211 នាក់ និងក្មេងស្រី 1,918 នាក់ (n=4,129) នៅថ្នាក់ទី 1 សម្រាប់ក្មេងប្រុសសរុបចំនួន 2,981 នាក់ និងក្មេងស្រី 2,613 នាក់ (n ៥.៥៩៤)។

3 ឧទាហរណ៍រួមមានការរៀនសូត្រដែលបានអនុវត្ត និងបទពិសោធន៍ ការភ្ជាប់ការរៀនសូត្រទៅនឹងបទពិសោធន៍ផ្ទាល់ខ្លួន និងការផ្តល់នូវព័ត៌មានតាមរយៈទម្រង់ និងវិធីសាស្ត្រជាច្រើន (Knowles, Holton, & Swanson, 2015)។

4 វិធីសាស្ត្របង្រៀន និងរៀនបែបសកលជួយគាំទ្រដល់សិស្សទាំងអស់ រួមទាំងអ្នកសិក្សាដែលជួបការលំបាក ដូចដែលបានពិពណ៌នានៅក្នុង Universal Design for Learning to Help All Children Read toolkit (Hayes, Turnbull, & Moran, 2018) និងធនធានដូចជាអ្វីដែលផ្តល់ដោយ CAST (2018) ជាដើម។

ទិន្នន័យដែលបានសង្កេតក្នុងអំឡុងពេលមេរៀនអំណានក៏បានបង្ហាញថា គ្រូបង្រៀន ACR-Cambodia ត្រូវបានផ្តល់ឧបករណ៍ដែលត្រូវការដើម្បីទទួលស្គាល់ និងគាំទ្រកុមារដែលជួបការលំបាក (ទោះបីជាគ្រូបង្រៀនមិនដឹងពីមូលហេតុនៃពិការភាពរបស់ពួកគេក៏ដោយ) ដោយផ្អែកលើគោលការណ៍បរិយាបន្នដែលបានបង្កប់ក្នុងសម្ភារៈបង្រៀន និងរៀន (TLMs) ។ ខណៈពេលដែលពុំមានទិន្នន័យដាច់ដោយឡែកនៃលទ្ធផលការសិក្សា របស់សិស្សដែលមានពិការភាព[5] ទិន្នន័យចុងក្រោEGRA របស់ ACR-Cambodia បានបង្ហាញពីលទ្ធផលសិក្សាកើនឡើងគួរឱ្យកត់សម្គាល់ក្នុងចំណោមសិស្សនៅក្នុងសាលារបស់គម្រោង ដែលនេះក៏បង្ហាញពីលទ្ធភាពដែលថា សិស្សមានពិការភាពដែលបានទទួលការបង្រៀនបែបបរិយាបន្នជាមួយគ្នានឹងមិត្តភក្តិរបស់ពួកគេដែលគ្មានពិការភាព ក៏អាចបង្កើនជំនាញអានរបស់ពួកគេផងដែរ។

**5. ផលវិបាកដែលមិនបានរំពឹងទុក៖** តើមានផលវិបាកដែលមិនបានរំពឹងទុកនៃសកម្មភាពដែរឬទេ? តើវាគឺជាអ្វី?



**ចំលើយ៖** នៅគ្រប់គម្រោង ផលវិបាកនានាបានកើតឡើង ដោយមិនត្រូវបានគេរំពឹងទុកនៅក្នុងពេលកសាងគម្រោង ។ ក្នុងករណី ACR-Cambodia ផលវិបាកទាំងនេះមានទាំងភាពវិជ្ជមាន និងអវិជ្ជមាន។ ខណៈពេលដែលជំងឺរាតត្បាតកូវីដ-១៩ បណ្តាលឱ្យមានការពន្យារពេល និងការកែសម្រួលគម្រោង ការវាយតម្លៃបានបង្ហាញពីភាពខ្លាំងនៃគម្រោងមួយចំនួនដែលទាក់ទងនឹងការគ្រប់គ្រងដែលមានភាពបត់បែន ការអភិវឌ្ឍសម្ភារៈអំណាន និងការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ។ ផលវិបាកដែលមិនបានរំពឹងទុកផ្សេងទៀតរួមមានកង្វះខាតទស្សនានានច្បាស់លាស់ អំពីការអប់រំបរិយាបន្នសម្រាប់ពិការភាព និងការយល់ខុសអំពីអត្រាប្រេវ៉ាឡង់នៃពិការភាពនៅក្នុងសហគមន៍ ដែលមិនត្រូវបានកែតម្រូវជាប់លាប់ក្នុងអំឡុងពេលអនុវត្តគម្រោង។ របកគំហើញដើម្បីគាំទ្រចម្លើយទាំងនេះ ក៏ដូចជាព័ត៌មានបន្ថែមអំពីកម្មវិធីស្តានចម្លងសម្រាប់សិស្សដែលស្តាប់មិនលឺ (មិនរាប់បញ្ចូលខាងលើ) ត្រូវបានរៀបរាប់លម្អិតនៅក្នុងរបាយការណ៍ពិស្តារ។ លើសពីនេះ របាយការណ៍នេះបង្ហាញពីការរកឃើញសំខាន់ៗដែលកើតចេញពីការអនុវត្តគម្រោង រួមទាំងព័ត៌មានដែលអាចផ្តល់ការយល់ដឹងសម្រាប់កិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីគាំទ្រការអប់រំបរិយាបន្នសម្រាប់ពិការភាព។

## 1.4 សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គេរដំណែលរបស់ ACR-Cambodia ទាំងភាពជោគជ័យ និងបញ្ហាប្រឈម ផ្តល់នូវចំណេះដឹងដ៏សំបូរបែបសម្រាប់សហគមន៍ពិភពលោកអំពីការអនុវត្តដ៏គួរឱ្យចាប់អារម្មណ៍នៃការអប់រំបរិយាបន្ន ដែលជាវិស័យសំខាន់ថ្មីមួយដែលត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍអន្តរជាតិ។ ACR-Cambodia មានការអនុវត្តប្រកបដោយជោគជ័យជាច្រើន ដូចជាវិធីសាស្រ្តសហការជាមួយរដ្ឋាភិបាល ការអភិវឌ្ឍ TLMs ដែលមានគុណភាពខ្ពស់ និងការផ្តោតលើការមិនបង្កគ្រោះថ្នាក់ដល់កុមារមានពិការភាព។ ACR-Cambodia ក៏បានជួយបំភ្លឺលើមេរៀនពិសោធន៍សម្រាប់គម្រោងនាពេលអនាគត រួមទាំងអនុសាសន៍ដែលអាចជួយដល់ការរចនា និងការអនុវត្តគម្រោង។ តារាងខាងក្រោមនេះនឹងសង្ខេបពីការសន្និដ្ឋាន និងអនុសាសន៍សំខាន់ៗមួយចំនួន ដែលត្រូវបានបញ្ជាក់បន្ថែមនៅក្នុងផ្នែកទី ៥ នៃរបាយការណ៍នេះ។

[5] ទិន្នន័យលទ្ធផលនៃការសិក្សាមិនត្រូវបានបែងចែកសម្រាប់ស្ថានភាពពិការភាពនៅក្នុងការកំណត់ការអប់រំទូទៅទេ ដោយសារបញ្ហាប្រឈមក្នុងការកំណត់អត្តសញ្ញាណសិស្សដែលមានពិការភាព។ ផ្ទុយទៅវិញ គម្រោងនេះបានសន្មតថាអត្រាប្រេវ៉ាឡង់នៃ 10% នៃអ្នកសិក្សាដែលមានពិការភាពដោយផ្អែកលើស្ថិតិជាតិ (Evans et al., 2014) ។

| តំបន់ EQ | មេរៀនវិជ្ជមានដែលបានទទួល | អនុសាសន៍សម្រាប់កម្មវិធីនាពេលអនាគត |
| --- | --- | --- |
| ដំណើរការ<br> | • ACR-Cambodia ធានាបាននូវកិច្ចសហការ ការទំនាក់ទំនង និងការគ្រប់គ្រងគម្រោងកម្រិតខ្ពស់ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់បង្កើតកម្មវិធីអប់រំខ្នាតធំ។<br>• USAID និង ACR-Cambodia បានប្រើប្រាស់វិធីសាស្ត្រ CLA ដើម្បីផ្តល់អត្ថប្រយោជន៍ដល់កម្មវិធីអប់រំបរិយាបន្ននៅក្នុងបរិបទថ្មី ដោយអនុញ្ញាតឱ្យមេរៀនដែលបានរៀនពីការអនុវត្តគម្រោងជួយជំរុញឱ្យមានការឆ្លើយតបប្រកបដោយក្រមសីលធម៌ហើយមិនបង្កគ្រោះថ្នាក់។ | • នៅក្នុងសេចក្តីអំពាវនាវការដាក់ពាក្យស្នើសុំគម្រោង ការអប់រំបរិយាបន្នដែលត្រូវដាក់បញ្ចូលនៅក្នុងគ្រប់ទិដ្ឋភាពនៃការរចនាគម្រោង ទាមទារឱ្យមានការចូលរួមពី OPD គួសបញ្ជាក់ទ្រឹស្តីនៃការផ្លាស់ប្តូរ និងកំណត់ពាក្យដូចជាពិការភាព និងការអប់រំបរិយាបន្ន ដើម្បីធានាថាភាគីពាក់ព័ន្ធមានការយល់ដឹងរួមដូចគ្នា។<br>• គាំទ្រគ្រូបង្រៀនឱ្យយល់ដឹងពីភាព ទូលំទូលាយនៃពិការភាព "ដែលមើលមិនឃើញ" ដើម្បីភ្ជាប់ការបណ្តុះបណ្តាលនៃការអប់រំបរិយាបន្នទៅនឹងបរិបទរបស់ពួកគេនៅពេលដែលសិស្សមានពិការភាព "អាចមើលឃើញ"មិនមានវត្តមាន។ |
| ការពិនិត្យធ្វើតេស្ត និងកំណត់អត្តសញ្ញាណ<br> | • មុនពេលអនុវត្តសកម្មភាពពិនិត្យធ្វើតេស្ត ACR-Cambodia បានរៀបចំផែនការណ៍នៃសេវាពិការភាព និងវិធីបញ្ជូនបន្ត ហើយបានចែករំលែកព័ត៌មាននេះជាមួយសាលារៀន។<br>• ACR-Cambodia បានបង្កើតជាគំរូតម្លាភាព ដោយការបោះពុម្ពផ្សាយការរកឃើញការពិនិត្យធ្វើតេស្តសាកល្បងរបស់ខ្លួន បើទោះបីជាលទ្ធផលមិនបានសមស្របតាមការរំពឹងទុកក៏ដោយ។ របាយការណ៍ត្រួតពិនិត្យរបស់ ACL-Cambodia (ឆ្នាំ ២០១៩) ផ្តល់នូវទិន្នន័យគ្រប់គ្រាន់ ការឆ្លុះបញ្ចាំង និងទស្សនាទាន ដើម្បីគម្រោងផ្សេងទៀតអាចជៀសវាងការប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានេះ។ | • រៀបចំផែនការឲ្យមានពេលវេលា និងធនធានគ្រប់គ្រាន់ (មនុស្ស និងសារពើពន្ធ) ដើម្បីសាកល្បង និងធ្វើឱ្យឧបករណ៍ពិនិត្យធ្វើតេស្តមានសុពលភាព អភិវឌ្ឍ និងកែលម្អពិធីការនៃការពិនិត្យធ្វើតេស្ត និងពិចារណាភាពជាដៃគូជាមួយសហគមន៍ និងធនធានសុខាភិបាល។ ការពិនិត្យធ្វើតេស្ត និងកំណត់អត្តសញ្ញាណនៅកម្រិតសាលា គឺជាការអនុវត្តជាក់ស្តែងដែលគេគួរពិចារណាយ៉ាងប្រុងប្រយ័ត្នក្នុងការរចនាកម្មវិធី។ ឧបករណ៍ដែលមានសុពលភាព និងអាចទុកចិត្តបានប្រហែលជាមិនមាននៅឡើយ។<br>• លើកទឹកចិត្តសាលារៀន និងគ្រូបង្រៀនឱ្យបន្តការអនុវត្តបែបបរិយាបន្នដែលស្របជាមួយ UDL ទោះបីជាការពិនិត្យធ្វើតេស្តមិនអាចដំណើរការបាន។ លើកកម្ពស់ការយល់ដឹងអំពីភាពចម្រុះនៃពិការភាព ផ្លាស់ប្តូរនូវការប្រើប្រាស់ពាក្យឱ្យបាន សមរម្យ និងផ្តោតលើគរុកោសល្យបរិយាបន្ន។ |
| ការបណ្តុះបណ្តាល<br> | • គម្រោងនេះបានធានាដល់ការអភិវឌ្ឍខ្លឹមសារនិងការបណ្តុះបណ្តាលប្រកបដោយការសហការគ្នាជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសគ្រូបណ្តុះបណ្តាលរបស់រដ្ឋាភិបាល និងអ្នកធ្វើការសម្រេចចិត្ត។<br>• ក្រុមការងារគម្រោងបានធានាថា ការរចនាការបណ្តុះបណ្តាលគឺឆ្លុះបញ្ចាំងពីគោលការណ៍សិក្សារបស់មនុស្សពេញវ័យ និង UDL រួមទាំងការប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីបង្ហាញព័ត៌មានដល់សិក្ខាកាម និងផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ការអនុវត្ត។<br>• ACR-Cambodia បានប្រើប្រាស់សិក្ខាសាលាបណ្តុះបណ្តាលគ្រូជាឱកាសដើម្បីមិនឱ្យមានការរើសអើងលើពិការភាព និងលើកកម្ពស់ការយល់ដឹងជុំវិញការអប់រំបរិយាបន្ន។ | • ធានាថាការបណ្តុះបណ្តាលដែលបង្កប់នូវគោលការណ៍អប់រំបរិយាបន្នមានលក្ខណៈផ្សារភ្ជាប់ច្បាស់លាស់ជាក់លាក់ មិនមែនដោយប្រយោលរវាងការអប់រំបរិយាបន្ន និងមុខវិជ្ជាដែលត្រូវបង្រៀន។<br>• ត្រូវប្រាកដថាមានការយកចិត្តទុកដាក់គ្រប់គ្រាន់ចំពោះសារសំខាន់ៗដែលទាក់ទងនឹងការបង្រៀនបែបបរិយាបន្ន ព្រោះថាការចំណាយពេលតិចពេកលើប្រធានបទអាចធ្វើឱ្យមានផលប៉ះពាល់ដល់ការបណ្តុះបណ្តាលលើការយល់ដឹង និងការអនុវត្តរបស់គ្រូ។<br>• ជានិច្ចកាលគួរបញ្ចូលជនមានពិការភាពជាអ្នកពាក់ព័ន្ធ និងជាសមភាគីក្នុងការសម្របសម្រួលវគ្គបណ្តុះបណ្តាល ហើយមិនត្រូវឱ្យសិក្ខាកាមដែលមិនមែនជាជនពិការធ្វើត្រាប់តាមបទពិសោធនៃការមានពិការភាពខ្លួនឯងឡើយ។ |

| តំបន់ EQ | មេរៀនវិជ្ជមានដែលបានទទួល | ការណែនាំអំពីកម្មវិធីនាពេលអនាគត |
|---|---|---|
| ការណែនាំ<br> | • គម្រោងនេះមានជោគជ័យក្នុងការអញ្ជើញក្រុមអ្នកពាក់ព័ន្ធជាច្រើននិងតំណាងក្រុមផ្សេងៗចូលរួមក្នុងការអភិវឌ្ឍ TLM ដែលធ្វើឲ្យសម្ភារៈទាំងនោះកាន់តែមានភាពសមស្របតាមបរិបទ និងមានតំណាងផ្នែកបរិយាបន្ន ទន្ទឹមនិងនោះជំរុញឲ្យមានការគាំទ្រ និងភាពជាម្ចាស់របស់ប្រទេសសាមី។<br>• ក្រុមការងារគម្រោងបានបង្កប់នូវយុទ្ធសាស្រ្តបង្រៀនដោយប្រយោល និងច្បាស់លាស់នៅក្នុងការណែនាំរបស់គ្រូ និងសម្ភារៈបន្ថែមដើម្បីបង្កើនការប្រើប្រាស់របស់ពួកគេដែលផ្តល់អត្ថប្រយោជន៍ដល់កុមារគ្រប់រូប។ | • សង្កត់ធ្ងន់និងបញ្ជាក់ឲ្យច្បាស់លាស់ក្នុងអំឡុងពេលបណ្តុះបណ្តាល និងក្នុងការបង្ហឹកអំពីអត្ថិភាពនៃពិការភាព “ដែលមើលមិនឃើញ” និងអំពីរបៀបអនុវត្តការបង្រៀនបរិយាបន្នដែលផ្តល់អត្ថប្រយោជន៍ដល់កុមារទាំងនេះ។<br>• សាកល្បង និងកែលម្អការវាយតម្លៃការអាន សម្រាប់កុមារមានពិការភាពដកស្រង់បទពិសោធពីកិច្ចខិតខំប្រឹងប្រែងចុងក្រោយបំផុតនៅក្នុងសហគមន៍អ្នកអនុវត្តកម្មវិធី EGR ។ |
| ផលវិបាកដែលមិនបានរំពឹងទុក<br> | • នៅដំណាក់កាលដំបូងៗនៃការអនុវត្ត ACR-Cambodia បានផ្តោតលើការបង្កើតទំនាក់ទំនងរឹងមាំជាមួយដៃគូរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ។ កិច្ចនេះបានធ្វើឲ្យក្រុមការងារគម្រោងមានភាពងាយស្រួលក្នុងការសម្របខ្លួនទៅនឹងលក្ខខណ្ឌប្រែប្រួលនានា ដូចជាការបិទសាលារៀនដែលទាក់ទងនឹងជំងឺរាតត្បាត។ | • កំណត់យ៉ាងច្បាស់នូវតួនាទីរបស់ក្រុមការងារបរិយាបន្នរបស់គម្រោង រួមទាំងរបៀបដែលក្រុមនេះត្រូវចូលរួមក្នុងគ្រប់ទិដ្ឋភាពនៃគម្រោង។ ផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកគម្រោងទាំងអស់អំពីការអប់រំបរិយាបន្ន ដោយមិនគិតពីតួនាទីរបស់ពួកគេ។<br>• អប់រំគ្រូបង្រៀន និងបុគ្គលិករដ្ឋាភិបាលអំពីពិការភាព “ដែលមើលមិនឃើញ” និងអត្រាប្រេវ៉ាឡង់ពិការភាពអន្តរជាតិ។ វាអាចជួយទប់ស្កាត់នឹងការយល់ខុសរបស់អ្នកពាក់ព័ន្ធដែលថាអត្រាប្រេវ៉ាឡង់ពិការភាពមានកម្រិតទាប នៅពេលដែលសកម្មភាពពិនិត្យធ្វើតេស្ត និងការកំណត់អត្តសញ្ញាណមិនផ្តល់លទ្ធផលដូចការរំពឹងទុក។ |
| កម្មវិធីស្ពានចម្លង<br> | • ក្រុមការងារគម្រោងមានភាពច្នៃប្រឌិតអំពីការប្រើប្រាស់ធនធានមនុស្ស និងសម្ភារៈនៅពេលផ្តល់ការអប់រំដល់សិស្សក្រៅសាលា។ ជាឧទាហរណ៍ ពួកគេបានប្រើប្រាស់អ្នកស្ម័គ្រចិត្តសហគមន៍ដើម្បីផ្តល់ការគាំទ្រផ្នែកបង្រៀន ទន្ទឹមនឹងនោះបានតស៊ូមតិដើម្បីឲ្យកុមារទទួលបានការអប់រំផ្លូវការក្នុងរយៈពេលវែង។<br>• ACR-Cambodia បានសហការជាមួយអ្នកជំនាញ CSL ដែលគថ្លង់ រួមទាំងតួអង្គរដ្ឋាភិបាល ដើម្បីបង្កើតធនធានសម្ភារៈបង្រៀន និងរៀនបន្ថែម (ដូចជាវីដេអូ CSL) សម្រាប់ប្រើប្រាស់នាពេលអនាគតនៅកម្រិតជាតិ។ | • ពិចារណាដោយប្រុងប្រយ័ត្នថាតើផលវិបាកអ្វីខ្លះអាចកើតឡើងពីការសាកល្បង ឬគំនិតផ្តួចផ្តើមអំពីកម្មវិធីអប់រំបរិយាបន្នសម្រាប់ពិការភាពដាច់ដោយឡែក ប្រសិនបើវាមិនអាចមាននិរន្តរភាព។ និរន្តរភាពនៃគំនិតផ្តួចផ្តើមដែលប្រើប្រាស់ធនធានច្រើន គឺជាបញ្ហាប្រឈមដ៏ធំមួយ។ នេះមិនមានន័យថា គំនិតផ្តួចផ្តើមនោះមិនគួរត្រូវបានបន្តនោះទេ ប៉ុន្តែគួរតែពិចារណាអំពីនិរន្តរភាពវាឱ្យបានឆាប់ និងញឹកញាប់។ |